# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ០៨ អនក្រ.បក

### ស្តីពីការផ្ទេរអតីតអាគារ និងក្របខ័ណ្ឌមន្ត្រីរាជការ ចលនទ្រព្យ អចលនទ្រព្យ និងឯកសារធ្វើការងារ វិស័យកិច្ចការនារី និងអតីតយុទ្ធជន ឲ្យមកស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន

----

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- អនុលោមតាមសេចក្តីសម្រេចរបស់កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ១៩៩៨

**សំរេច**

**មាត្រា ១.** ផ្ទេរអតីតអាគារ រួមទាំងចលនទ្រព្យ និងអចលនទ្រព្យទាំងអស់របស់នាយកដ្ឋានគោលនយោបាយអតីតយុទ្ធជន និងនាយកដ្ឋានអភិវឌ្ឍន៍អតីតយុទ្ធជន នៃអតីតក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន និងអាគារទីស្តីការ រួមទាំងចលនទ្រព្យ និងអចលនទ្រព្យទាំងអស់នៃអតីតក្រសួងកិច្ចការនារី អង្គភាពមូលដ្ឋាន ខេត្ត-ក្រុង-ស្រុក-ខណ្ឌ ធ្វើការងារវិស័យកិច្ចការនារី និងអតីតយុទ្ធជន ឲ្យមកស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ។

**មាត្រា ២.** ប្រើប្រាស់អាគារទីស្តីការ នៃអតីតក្រសួងកិច្ចការនារីនាបច្ចុប្បន្ន ដែលមានចែងក្នុងមាត្រា ១ខាងលើ សំរាប់ធ្វើជាទីស្តីការក្រសួងកិច្ចការនារី និងអតីតយុទ្ធជន បណ្តោះអាសន្នសិន ។

**មាត្រា ៣.** ផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការទាំងអស់ នៃអតីតក្រសួងកិច្ចការនារី និងក្របខ័ណ្ឌមន្ត្រីរាជការព្រមទាំងបុគ្គលិកទាំងអស់ នៃនាយកដ្ឋានគោលនយោបាយអតីតយុទ្ធជន នាយកដ្ឋានអភិវឌ្ឍន៍អតីតយុទ្ធជន និងក្របខ័ណ្ឌមន្ត្រីរាជការព្រមទាំងបុគ្គលិកនៅមូលដ្ឋានខេត្ត-ក្រុង ស្រុក ខណ្ឌដែលធ្វើការងារវិស័យអតីតយុទ្ធជនរបស់អតីតក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជនឲ្យមកស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជនវិញ ។

www.pheakdeylaw.com

មាត្រា ៤ ._ បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ក្រុងកែប ក្រុងប៉ៃលិន អភិបាលខេត្ត-ក្រុង មានភារកិច្ចអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ០៥ អនក្រ.បក
## ស្តីពីការបែងចែកចំណូលថវិកាទូទៅរបស់រដ្ឋ
## តាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៩

---

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម នស/រកម/០១៩៩/០១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៩
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

www.pheakdeylaw.com